# សិទ្ធិ និងការពាររបស់អ្នកទប់ទល់នឹងវិក្កយបត្រពេទ្យដែលមិនដឹងជាមុន

នៅពេលអ្នកទទួលបានការថែទាំសង្គ្រោះបន្ទាន់ ឬទទួលបានការព្យាបាលពីអ្នកផ្តល់សេវានៅក្រៅបណ្តាញ នៅឯមន្ទីរពេទ្យមួយក្នុងបណ្តាញ ឬនៅមជ្ឈមណ្ឌលវះកាត់សង្គ្រោះបន្ទាន់ អ្នកត្រូវបានការពារពីការចេញវិក្កយបត្រដែលមិនដឹងជាមុន ឬវិក្កយបត្រសមតុល្យ ។

**<u>តើអ្វីទៅជា "វិក្កយបត្រសមតុល្យ" (ជួនកាលគេហៅថា "វិក្កយបត្រដែលមិនដឹងជាមុន") ?</u>**

នៅពេលអ្នកជួបគ្រូពេទ្យម្នាក់ ឬអ្នកផ្តល់សេវាថែទាំសុខភាពដទៃទៀត អ្នកអាចជាប់ជំពាក់ថ្លៃចំណាយក្រៅហោប៉ៅខ្លះៗ ដូចជា ថ្លៃបង់មុន ថ្លៃសហធានារ៉ាប់រង និង/ឬថ្លៃដែលអាចកាត់យកបាន ។ អ្នកអាចមានការចំណាយដទៃទៀត ឬត្រូវបង់ថ្លៃវិក្កយបត្រទាំងអស់ បើសិនអ្នកជួបអ្នកផ្តល់សេវាម្នាក់ ឬទៅកាន់មន្ទីរថែទាំសុខភាពមួយ ដែលមិនស្ថិតក្នុងបណ្តាញរបស់គម្រោងសុខភាពរបស់អ្នក ។

"ក្រៅបណ្តាញ" មានន័យថា អ្នកផ្តល់សេវា និងមន្ទីរថែទាំសុខភាពទាំងឡាយណាដែលមិនបានចុះហត្ថលេខាជាមួយគម្រោងសុខភាពរបស់អ្នក ។ អ្នកផ្តល់សេវាក្រៅបណ្តាញ អាចត្រូវបានគេអនុញ្ញាតឲ្យចេញវិក្កយបត្រឲ្យអ្នកសម្រាប់ភាពខុសគ្នារវាងអ្វីដែលគម្រោងរបស់អ្នកបានយល់ព្រមបង់ និងទឹកប្រាក់សរុបដែលបានយកថ្លៃសេវាមួយ ។ នេះគេហៅថា "**វិក្កយបត្រសមតុល្យ**" ។ ទឹកប្រាក់នេះទំនងជាច្រើនជាងការចំណាយក្នុងបណ្តាញសម្រាប់សេវាដូចគ្នា ហើយប្រហែលជាមិនអាចរាប់បញ្ចូលក្នុងដែនកំណត់ក្រៅហោប៉ៅប្រចាំឆ្នាំរបស់អ្នកបានឡើយ ។

"វិក្កយបត្រដែលមិនដឹងជាមុន" គឺជាវិក្កយបត្រសមតុល្យដែលគេមិនបានរំពឹងទុក ។ រឿងនេះអាចកើតឡើងនៅពេលអ្នកមិនអាចត្រួតពិនិត្យបានថានរណាខ្លះដែលចូលរួមពាក់ព័ន្ធក្នុងការថែទាំរបស់អ្នក—ដូចជានៅពេលអ្នកមានការសង្គ្រោះបន្ទាន់ ឬនៅពេលអ្នកគ្រោងទៅជួបពិនិត្យនៅឯមន្ទីរថែទាំក្នុងបណ្តាញមួយ ប៉ុន្តែទទួលបានការព្យាបាលដោយមិនបានរំពឹងទុកពីអ្នកផ្តល់សេវាក្រៅបណ្តាញទៅវិញ ។

<u>អ្នកត្រូវបានគេការពារពីការចេញវិក្កយបត្រសមតុល្យសម្រាប់៖</u>

**សេវាសង្គ្រោះបន្ទាន់**
បើសិនអ្នកមានស្ថានភាពសុខភាពត្រូវសង្គ្រោះបន្ទាន់ ហើយទទួលបានសេវាកម្មសង្គ្រោះបន្ទាន់ពីអ្នកផ្តល់សេវា ឬមន្ទីរថែទាំក្រៅបណ្តាញមួយ ទឹកប្រាក់ច្រើនបំផុតដែលអ្នកផ្តល់សេវា ឬមន្ទីរថែទាំអាចចេញវិក្កយបត្រឲ្យអ្នកគឺចំនួននៃចំណែកការចំណាយក្នុងបណ្តាញនៃគម្រោងរបស់អ្នក (ដូចជា ថ្លៃបង់មុន និងថ្លៃសហធានារ៉ាប់រង) ។ អ្នក**មិនអាច**ឲ្យគេចេញវិក្កយបត្រសម្រាប់សេវាកម្មសង្គ្រោះបន្ទាន់ទាំងនេះឡើយ ។ នេះរាប់បញ្ចូលទាំងសេវាកម្មទាំងឡាយដែលអ្នកទទួលបាន ក្រោយពេលអ្នកស្ថិតក្នុងស្ថានភាពបិតថេរ លុះត្រាតែអ្នកផ្តល់ការអនុញ្ញាតជាលាយលក្ខណ៍អក្សរ ហើយបោះបង់ការការពាររបស់អ្នក មិនឲ្យគេចេញវិក្កយបត្រសមតុល្យសម្រាប់សេវាកម្មក្រោយស្ថានភាពបិតថេរទាំងនេះ ។

**សូមកត់សម្គាល់ថា ក្រោមច្បាប់រដ្ឋ Arkansas បើសិនអ្នកទទួលបានសេវាកម្មមិនមែនសង្គ្រោះបន្ទាន់ពីអ្នកផ្តល់សេវាកម្ម ឬមន្ទីរថែទាំក្រៅបណ្តាញ អ្នកអាចត្រូវបានគេចេញវិក្កយបត្រសមតុល្យ ឬអ្នកអាចទទួលខុសត្រូវចំពោះថ្លៃវិក្កយបត្រទាំងអស់ ។** ប៉ុន្តែអ្នកអាចនៅតែទទួលបានការការពារក្រោមបម្រាមការចេញវិក្កយបត្រសមតុល្យរបស់សហព័ន្ធ ។

**សេវាកម្មមួយចំនួននៅឯមន្ទីរពេទ្យ ឬមជ្ឈមណ្ឌលវះកាត់សង្គ្រោះបន្ទាន់ក្នុងបណ្តាញ**
នៅពេលអ្នកទទួលបានសេវាកម្មពីមន្ទីរពេទ្យ ឬមជ្ឈមណ្ឌលវះកាត់សង្គ្រោះបន្ទាន់ក្នុងបណ្តាញ អ្នកផ្តល់សេវាមួយចំនួននៅទីនោះអាចស្ថិតនៅក្រៅបណ្តាញ ។ ក្នុងករណីទាំងនេះ ទឹកប្រាក់ច្រើនបំផុតដែលអ្នកផ្តល់សេវាទាំងនោះអាចចេញវិក្កយបត្រឲ្យអ្នកគឺ ចំនួននៃចំណែកថ្លៃចំណាយក្នុងបណ្តាញនៃគម្រោងរបស់អ្នក ។ នេះអនុវត្តចំពោះសេវាកម្មថ្នាំសង្គ្រោះបន្ទាន់ ការប្រើថ្នាំសន្លប់ រោគសាស្ត្រ វិទ្យុសាស្ត្រ មន្ទីរពិសោធន៍ វិជ្ជាថែទាំទារកទើបកើត ជំនួយការគ្រូពេទ្យវះកាត់ គ្រូពេទ្យប្រចាំការ ឬគ្រូពេទ្យព្យាបាលជំងឺធ្ងន់ ។ អ្នកផ្តល់សេវាទាំងនេះ**មិនអាច**ចេញវិក្កយបត្រសមតុល្យឲ្យអ្នក ហើយ**មិនអាច**សុំឲ្យអ្នកបោះបង់ការការពាររបស់អ្នកមិនឲ្យគេចេញវិក្កយបត្រសមតុល្យឡើយ ។

*ខ្លឹមសារនៃឯកសារនេះមិនមានកម្លាំង និងឥទ្ធិពលច្បាប់ឡើយ ហើយមិនមានគោលបំណងបង្ខាប់ឲ្យសាធារណជនគោរពតាមដែរ ទោះក្នុងរបៀបណាក៏ដោយ លុះត្រាតែមានដាក់បញ្ចូលជាពិសេសក្នុងកិច្ចសន្យា ។ ឯកសារនេះមានគោលបំណងក្នុងការផ្តល់ភាពច្បាស់លាស់ទៅដល់សាធារណជនទាក់ទងនឹងលក្ខខណ្ឌតម្រូវមានស្រាប់ដែលស្ថិតក្រោមច្បាប់នេះ ។*

បើសិនអ្នកទទួលបានសេវាកម្មដទៃទៀតនៅឯមន្ទីរថែទាំក្នុងបណ្ដាញទាំងនេះ អ្នកផ្ដល់សេវាកម្មក្រៅបណ្ដាញ**មិនអាច**ចេញវិក្កយបត្រសមតុល្យឲ្យអ្នកបានឡើយ លុះត្រាតែអ្នកផ្ដល់ការអនុញ្ញាតជាលាយលក្ខណ៍អក្សរ ហើយបោះបង់ការការពាររបស់អ្នក ។

**គេមិនដែលតម្រូវឲ្យអ្នកបោះបង់ការការពាររបស់អ្នកពីការចេញវិក្កយបត្រសមតុល្យឡើយ ។ គេក៏មិនតម្រូវឲ្យអ្នកផងដែរក្នុងការទទួលការថែទាំក្រៅបណ្ដាញ។ អ្នកអាចជ្រើសរើសអ្នកផ្ដល់សេវា ឬមន្ទីរថែទាំក្នុងបណ្ដាញគម្រោងរបស់អ្នក ។**

**សូមកត់សម្គាល់ថា ក្រោមច្បាប់រដ្ឋ Arkansas បើសិនអ្នកទទួលបានសេវាកម្មមិនមែនសង្គ្រោះបន្ទាន់ពីអ្នកផ្ដល់សេវាកម្ម ឬមន្ទីរថែទាំក្រៅបណ្ដាញ អ្នកអាចត្រូវបានគេចេញវិក្កយបត្រសមតុល្យ ឬអ្នកអាចទទួលខុសត្រូវចំពោះថ្លៃវិក្កយបត្រទាំងអស់ ។** ប៉ុន្តែអ្នកអាចនៅតែទទួលបានការការពារក្រោមបម្រាមការចេញវិក្កយបត្រសមតុល្យរបស់សហព័ន្ធ ។

**នៅពេលដែលវិក្កយបត្រសមតុល្យមិនត្រូវបានអនុញ្ញាត អ្នកក៏មានការការពារដូចខាងក្រោមដែរ៖**

- អ្នកទទួលខុសត្រូវចំពោះការបង់ចំណែកថ្លៃចំណាយរបស់អ្នកប៉ុណ្ណោះ (ដូចជា ថ្លៃបង់មុន ថ្លៃសហធានារ៉ាប់រង និងថ្លៃដែលអាចកាត់យកបាន ដែលអ្នកបង់ បើសិនអ្នកផ្ដល់សេវា ឬមន្ទីរថែទាំគឺស្ថិតនៅក្នុងបណ្ដាញ) ។ គម្រោងសុខភាពរបស់អ្នកនឹងទូទាត់ទៅឲ្យអ្នកផ្ដល់សេវាកម្មក្រៅបណ្ដាញ និងមន្ទីរថែទាំដោយផ្ទាល់ ។

- ជាទូទៅ គម្រោងសុខភាពរបស់អ្នកត្រូវតែ៖

    - ចេញថ្លៃសេវាសង្គ្រោះបន្ទាន់ដោយមិនតម្រូវឲ្យអ្នកមានការយល់ព្រមជាមុនសម្រាប់សេវាកម្មទាំងនេះឡើយ (ការអនុញ្ញាតជាមុន) ។

    - ចេញថ្លៃសេវាសង្គ្រោះបន្ទាន់ផ្ដល់ជូនដោយអ្នកផ្ដល់សេវាកម្មក្រៅបណ្ដាញ ។

    - ផ្អែកអ្វីដែលអ្នកជំពាក់អ្នកផ្ដល់សេវា ឬមន្ទីរថែទាំ (ការចែករំលែកការចំណាយ) លើអ្វីដែលគួរទូទាត់ទៅឲ្យអ្នកផ្ដល់សេវា ឬមន្ទីរថែទាំក្នុង-បណ្ដាញ ហើយបង្ហាញពីចំនួនទឹកប្រាក់នោះក្នុងការបរិយាយនៃអត្ថប្រយោជន៍របស់អ្នក ។

    - រាប់ចំនួនទឹកប្រាក់ដែលអ្នកបង់សម្រាប់សេវាសង្គ្រោះបន្ទាន់ ឬសេវាក្រៅបណ្ដាញបញ្ចូលក្នុងដែនកំណត់នៃថ្លៃដែលអាចកាត់យកបាន និងក្រៅហោប៉ៅរបស់អ្នក ។

**បើសិនអ្នកជឿជាក់ថា គេបានចេញវិក្កយបត្រឲ្យអ្នកខុស** អ្នកអាចទាក់ទងទៅផ្នែកផ្ដល់ជំនួយខាងគ្មានការភ្ញាក់ផ្អើលនៃក្រសួងសេវាកម្មសុខាភិបាល និងប្រជាជន តាមលេខ 1-800-985-3059 ។ អ្នកក៏អាចដាក់បណ្ដឹងទៅផ្នែកធានារ៉ាប់រងរដ្ឋ Arkansas ដោយចូលទៅកាន់វេបសាយនេះ៖ https://sbs.naic.org/solar-web/pages/public/onlineComplaintForm/onlineComplaintForm.jsf?state=AR&dswid=5160.

ចូលទៅកាន់ https://www.cms.gov/nosurprises សម្រាប់ព័ត៌មានបន្ថែមអំពីសិទ្ធិរបស់អ្នកក្រោមច្បាប់សហព័ន្ធ ។

*ខ្លឹមសារនៃឯកសារនេះមិនមានកម្លាំង និងឥទ្ធិពលច្បាប់ឡើយ ហើយមិនមានគោលបំណងបង្គាប់ឲ្យសាធារណជនគោរពតាមដែរ ទោះក្នុងរបៀបណាក៏ដោយ លុះត្រាតែមានដាក់បញ្ចូលជាពិសេសក្នុងកិច្ចសន្យា ។ ឯកសារនេះមានគោលបំណងក្នុងការផ្ដល់ភាពច្បាស់លាស់ទៅដល់សាធារណជនទាក់ទងនឹងលក្ខខណ្ឌតម្រូវមានស្រាប់ដែលស្ថិតក្រោមច្បាប់នេះ ។*